ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២១៣ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

(ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៤)

២០២៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២១៣...អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈ-កម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៦៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៣/២៣១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈ-កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌

- បានឃើញអនុក្រឹត្យលេខ ៣២៥ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើត **យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល** ដែលសរសេរជាអក្សរកាត់ថា "**យ.ស.ក.**" ដើម្បីធានាសុខដុមនីយកម្មរវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ច្បាប់ ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

## ជំពូកទី២
## មុខងារនិងភារកិច្ច

**មាត្រា២ .-**

**យ.ស.ក**. ជាយន្តការដឹកនាំនិងសម្របសម្រួលផ្លាស់វេនប្រចាំត្រីមាស រវាងលេខាធិការដ្ឋាននៃគណៈ-កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។

**មាត្រា៣ .-**

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ជាប្រធានទទួលវេនដឹកនាំនិងសម្របសម្រួល **យ.ស.ក.** មានភារកិច្ចដូចតទៅ៖

- សិក្សានិងកំណត់បញ្ហាប្រឈមនិងសំណើដំណោះស្រាយទាំងឡាយដែលមានចរិតអន្តរកែទម្រង់ ដើម្បីជាប្រធានបទពិភាក្សានិងសម្រេចក្នុងក្របខ័ណ្ឌ **ឃ.ស.ក.**
- ដឹកនាំនិងសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗព្រមទាំងលើកសំណើសកម្មភាពឬសំណើដំណោះស្រាយជាគម្រោងការងារឬបេសកកម្មការងារដែលមានចរិតលក្ខណៈអន្តរកែទម្រង់ តាមសំណើរបស់លេខាធិការដ្ឋានកែទម្រង់ណាមួយ តាមបង្គាប់របស់ប្រធានគណៈកម្មាធិការកែទម្រង់ ឬតាមការចាំបាច់
- តាមដានរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ របស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារដែលមានចរិតអន្តរកែទម្រង់ ដោយប្រើប្រាស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ជាមជ្ឈមណ្ឌលកណ្ដាលក្នុងការសម្របសម្រួលនិងបូកសរុបរបាយការណ៍រួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈរដ្ឋបាលរាជធានី ខេត្ត
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ទាំង ៥ នៃរាជរដ្ឋាភិបាល
- រៀបចំនិងកំណត់របៀបវារៈប្រជុំ **ឃ.ស.ក.** ប្រចាំត្រីមាស ប្រចាំឆ្នាំ ឬតាមការចាំបាច់
- រៀបចំនិងធានាដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់
- រៀបចំរបាយការណ៍កិច្ចប្រជុំជូនប្រធានគណៈកម្មាធិការកែទម្រង់ទទួលបន្ទុក ស្របតាមនីតិវិធីដូចមានកំណត់ក្នុងអនុក្រឹត្យនេះ
- រៀបចំ សម្របសម្រួល និងដឹកនាំការងារអន្តរកែទម្រង់ផ្សេងទៀតតាមការចាំបាច់។

## ជំពូកទី៣
## ការប្រព្រឹត្តទៅ

**មាត្រា៤ .-**

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវម្ចាស់ការសម្របសម្រួលស្ថាប័ននិងអង្គភាពដែលជាតួអង្គអនុវត្តពាក់ព័ន្ធក្រោមកម្មវិធីកែទម្រង់រៀងៗខ្លួន ក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាព របាយការណ៍ និងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីធានាការចូលរួមអនុវត្ត **ឃ.ស.ក.** ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព។

**មាត្រា៥ .-**

អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ដែលជាប្រធានទទួលវេនត្រីមាសនីមួយៗគឺជាប្រធាន **ឃ.ស.ក.** ប្រចាំត្រីមាសនោះ។ ក្នុងករណីប្រធានអវត្តមានឬករណីចាំបាច់ អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ អាចប្រគល់សិទ្ធិនេះជូនអគ្គលេខាធិការរង ឬ អនុប្រធានលេខាធិការដ្ឋានទទួលបន្ទុក ដឹកនាំជំនួសបាន។

ប្រធាន **ឃ.ស.ក**.ត្រូវធានាការអនុវត្តតាមតួនាទីនិងភារកិច្ចដូចមានកំណត់ក្នុងមាត្រា ៤ ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់។

ប្រធាន **ឃ.ស.ក**. ត្រូវដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គ-លេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ។

**មាត្រា៦ .-**

ក្នុងករណីចាំបាច់ឬមានសំណើពីអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ណាមួយខាងលើ ការទទួលនិងដឹកនាំសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសអាចប្រព្រឹត្តទៅក្រោមទម្រង់ជាសហប្រធាន។

**មាត្រា៧ .-**

ប្រធាន **ឃ.ស.ក**. មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន និងតំណាងអង្គភាពក្រោមឱវាទក្រសួង ដឹកនាំការងារកែទម្រង់នីមួយៗ ចូលរួមប្រជុំបានតាមការចាំបាច់។

ប្រធាន **ឃ.ស.ក**. អាចអញ្ជើញ ដៃគូអភិវឌ្ឍនានា ចូលរួមប្រជុំបានតាមការចាំបាច់។

**មាត្រា៨ .-**

**ឃ.ស.ក**. ត្រូវមានផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវអនុម័តយ៉ាងយូរក្នុងសប្តាហ៍ទី៤នៃឆ្នាំបន្ទាប់។ អគ្គលេខា-ធិការដ្ឋាន ឬ លេខាធិការដ្ឋានជាប្រធានទទួលវេនប្រចាំត្រីមាសទី៤ និងត្រីមាសទី១នៃឆ្នាំបន្ទាប់ ត្រូវសហការគ្នានិងទទួលខុសត្រូវរៀបចំ និងបូកសរុបផែនការសកម្មភាព ប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

**មាត្រា៩ .-**

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវរៀបចំ បូកសរុប ត្រួតពិនិត្យតាមដាន និងត្រូវដាក់ជារបៀបវារៈពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការកែទម្រង់ទាំង៥ មានសិទ្ធិចេញសេចក្តីសម្រេចរួមដើម្បីកំណត់វិធាននិងនីតិវិធីលម្អិតនៃការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាព។

**មាត្រា១០ .-**

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវរៀបចំឡើងយ៉ាងយូរបំផុតនៅក្នុងសប្តាហ៍ទី ៤ នៃត្រីមាសបន្ទាប់។

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវសម្រេចលើរបៀបវារៈកំណត់ដោយប្រធានកិច្ចប្រជុំ និងត្រូវសម្រេចលើការកំណត់អគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់ ដែលត្រូវទទួលបន្ទុកជាប្រធាន **ឃ.ស.ក**. នៃត្រីមាស បន្ទាប់។

របាយការណ៍កិច្ចប្រជុំ ត្រូវរៀបចំគោរពជូនប្រធានគណៈកម្មាធិការកែទម្រង់ដែលជាប្រធានទទួលវេនដើម្បីពិនិត្យនិងសម្រេច មុននឹងចម្លងជូនអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដើម្បីពិនិត្យនិងសហការអនុវត្ត។

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ប្រធាន **ឃ.ស.ភ.** អាចស្នើសុំរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិភាក្សានិងលើកសំណើដំណោះស្រាយចំពោះបញ្ហាប្រឈមជាក់លាក់ណាមួយ។

**មាត្រា១១ .-**

ក្នុងករណីដែលអគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានជាប្រធានទទួលវេន ខកខានឬយឺតយ៉ាវក្នុងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសតាមថិរវេលាខាងលើ អគ្គលេខាធិការដ្ឋានឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតអាចមានសិទ្ធិទទួលភារកិច្ចជំនួសបានដើម្បីធានាប្រក្រតីភាព ភាពជាម្ចាស់ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

## **ជំពូកទី៤**

## **អវសានប្បញ្ញត្តិ**

**មាត្រា១២ .-**

អនុក្រឹត្យលេខ ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាលនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ